# ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៦-០២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/០២០៤/០២៨ ស្តីពីការត្រូវបានបញ្ចប់អាណត្តិបច្ចុប្បន្នជាទីប្រឹក្សាផ្ទាល់ស្តេចក្រុមឃុនអនុប្រធានទី ១ នៃព្រឹទ្ធសភា ចំពោះឯកឧត្តម **គុជ ស៊ីនិត** និង ឯកឧត្តម **សោម ឆេង** | ៣៩០ |
| ២៣-០២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/០២០៤/០៣៥ ស្តីពីការតែងតាំង លោក **វ៉ាន់ សុខុន** ជា ឧកញ៉ា | ៣៩១ |
| ២៣-០២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/០២០៤/០៣៧ ស្តីពីការប្រោសព្រះរាជទានចំពោះឧកញ៉ា **ណា ម៉ារឌី** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា | ៣៩២ |
| ២៣-០២-២០០៤ | -ព្រះរាជក្រឹត្យនស/រកត/០២០៤/០៣៩ ស្តីពីការផ្ទេរបញ្ចូលលោក **ស្រី សុបិន** ទៅក្នុងឋានន្តរសក្តិវរមន្ត្រីថ្នាក់លេខ៤នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ | ៣៩៣ |


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ០៤-៣-២០០៤ | -អនុក្រឹត្យលេខ ១១០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៣៩៤ |
| ០៤-៣-២០០៤ | -អនុក្រឹត្យលេខ ១១១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៣៩៥ |
| ០៤-៣-២០០៤ | -អនុក្រឹត្យលេខ ១១២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរសក្តិពីអនុមន្ត្រីការបរទេស ទៅឋានន្តរសក្តិវរមន្ត្រីការបរទេស នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ | ៣៩៦ |
| ០៤-៣-២០០៤ | -អនុក្រឹត្យលេខ ១១៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៣៩៩ |
| ០៥-៣-២០០៤ | -អនុក្រឹត្យលេខ ១១៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៤០១ |
| ០៥-៣-២០០៤ | -អនុក្រឹត្យលេខ ១១៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៤០២ |
| ០៥-៣-២០០៤ | -អនុក្រឹត្យលេខ ១១៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៤០៣ |
| ០៥-៣-២០០៤ | -អនុក្រឹត្យលេខ ១១៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៤០៤ |
| ០៩-៣-២០០៤ | -អនុក្រឹត្យលេខ ១១៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៤០៥ |


## III-ការិយាល័យក្រសួង

### ១-ទីស្តីការក្រសួងមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ


| | | |
|---|---|---|
| ០២-៣-២០០៤ | -ប្រកាសលេខ ០៨៦ ប្រក.កសក ស្តីពីការដាក់ឱ្យប្រើបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា | ៤០៦ |
| ០២-៣-២០០៤ | -ប្រកាសលេខ ០៨៩ ប្រក.កសក.ប ស្តីពីការតែងតាំងមន្ត្រីរាជការ | ៤១១ |

# ខ

## ២.នីតិការរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


០១-៣-២០០៤ -ប្រកាសលេខ ០៧០ សហវ.ប្រក ស្តីពីការបន្ថែមសមាជិកទៅក្នុងក្រុមប្រតិបត្តិសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ៤២០

០២-៣-២០០៤ -ប្រកាសលេខ ០៧១ សហវ.ប្រក ស្តីពីការបង្កើតគណៈកម្មាធិការសំរាប់កិច្ចសហប្រតិបត្តិការវិស័យហិរញ្ញវត្ថុ រវាង កម្ពុជា និង ជប៉ុន របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ៤២២

០៤-៣-២០០៤ -ប្រកាសលេខ ០៨០ សហវ.ពដ ស្តីពីការបំពេញបន្ថែមលើការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៣ ៤២៤

០៤-៣-២០០៤ -សេចក្តីជូនដំណឹងលេខ ០០៤ សហវ.សជណ ស្តីពីការអញ្ជើញម្ចាស់យានយន្តគ្រប់ប្រភេទដែលពុំទាន់បង់ពន្ធឱ្យមកបំពេញកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ ៤២៧

# ព្រះរាជក្រឹត្យ

នស/រកត/០២០៤/០៧៨

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកត/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៩៩

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់ បង្គាប់តែងតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា

-យោងតាមសំណើរបស់ស្តេចក្រុមឃុន ស៊ីសុវត្ថិ ជីវ៉ាន់មុនីរ័ក្ស អនុប្រធានទី១ នៃព្រឹទ្ធសភា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ត្រូវបានបញ្ចប់អណត្តិបច្ចុប្បន្នជាទីប្រឹក្សាផ្ទាល់ស្តេចក្រុមឃុនអនុប្រធានទី១ នៃព្រឹទ្ធសភា ចំពោះឯកឧត្តមដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម **គុជ ស៊ីនិត**

២-ឯកឧត្តម **សោម ឆេង**

**មាត្រា ២ :** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

លេខៈ ៦៩.ចអ **ហត្ថលេខា និងព្រះរាជលញ្ឆករ**

ពរស.០៤.០២.០៧៨ ជើងប្រឹក្សាបួបផែក **ជា ស៊ីម**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិនា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ ឥសាន**

**ណាវី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០២០៤/០៣៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

( បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា )

តែងតាំង

លោក ទ្វៃ ស៊ុខន

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាសំបទ្ទាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

លេខ: ២៦ .ចល

៣៧ល.០៤.០២.០៣៥ ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០២០៤/០៣៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត ជិសុទ្ធពង្ស អគ្គមហាបុរសរតនៈ

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់ឃើញសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា)

ត្រាស់ព្រះរាជទាន

ចំពោះ

ឧកញ៉ា **ណរា ម៉ារឌី**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ ២០០៤

ឡុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

លេខៈ ...

**ជា ស៊ីម**

៣៩ស.០៤.០២.០៣៧

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

# ព្រះរាជក្រឹត្យ

ជស/រកត/០២០៤/០៣៩

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្ទេរបញ្ចូល លោក ស្រី សុបិន ទៅក្នុងឋានន្តរសក្តិវរមន្ត្រី ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៤

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

លេខ: ២១៩ ច.ល

ពរស.០៤.០២.០៣៩

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ៣ ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃ ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**ស ម្រេ ច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន ០៤រូប ដែលបានខិតខំ ខ្នះខ្នែងក្នុងការដឹកនាំ និង បានបរិច្ចាគធនធាន ចូលរួមជួយកសាងព្រះវិហារ និង អគារសិក្សា នៅក្នុង វត្ត*ទួលរវៀង* ឃុំស្មោងខាងត្បូង ស្រុកកំចាយមារ ខេត្តព្រៃវែង ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ អ៊ុម រី ព្រះចៅអធិការវត្តរវៀង អ្នកផ្តើមគំនិត និង ដឹកនាំកសាងសមិទ្ធផល

២-លោកស្រី ញ៉ើម សាវ៉ាន ថវិកា ចំនួន ២៥.០០០ ដុល្លារ និង ៥.០០០.០០០ រៀល

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក ហេន ឡុង ថវិកា ចំនួន ២៣.០០០.០០០ រៀល

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

-លោក ម៉ាត់ សាឌុង ថវិកា ចំនួន ៨.០០០.០០០ រៀល

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា២ នៃអនុក្រឹត្យ
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ប្រគេនព្រះគ្រូ រតនរតោ **ឈៅ ឈាន** ព្រះអនុគណ ស្រុកមង្គលបូរី ដែលបានបរិច្ចាគបច្ច័យ ចូលរួមចំណែកក្នុងការកសាង សាលាពុទ្ធិកបឋមសិក្សា នៅក្នុងវត្ត ឫស្សីក្រោក ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ចំណាយអស់បច្ច័យផ្ទាល់ព្រះអង្គ ចំនួន ១៣.២៣០ ដុល្លារអាមេរិក ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ៦៧ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

(9)

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិពីអនុមន្ត្រីការបរទេស ទៅឋានន្តរស័ក្តិវរមន្ត្រីការបរទេស នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់

* * * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**មាត្រា ១ .-**

ត្រូវបានតម្លើងឋានន្តរស័ក្តិពីអនុមន្ត្រីការបរទេស ទៅក្នុងឋានន្តរស័ក្តិវរមន្ត្រីការបរទេស នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នូវមន្ត្រីរាជការស៊ីវិល ដូចមានរាយនាមខាងក្រោម ÷

| | | | |
|---|---|---|---|
| ០១ | លោក **អ៊ិត សីលា** | វរមន្ត្រី | ថ្នាក់លេខ ៧ |
| ០២ | លោក **សំ រដេខ** | វរមន្ត្រី | ថ្នាក់លេខ ៧ |
| ០៣ | លោក **សរ ស៊ីផារន** | វរមន្ត្រី | ថ្នាក់លេខ ៧ |
| ០៤ | លោក **និត សារុនរ៉ែត** | វរមន្ត្រី | ថ្នាក់លេខ ៧ |
| ០៥ | លោក **ឡាយ យ៉ែម** | វរមន្ត្រី | ថ្នាក់លេខ ៧ |
| ០៦ | លោក **គីម សារិន** | វរមន្ត្រី | ថ្នាក់លេខ ៧ |
| ០៧ | លោក **សោម ស៊ុណ្ណា** | វរមន្ត្រី | ថ្នាក់លេខ ៧ |
| ០៨ | លោក **ស៊ឹម សុខុម** | វរមន្ត្រី | ថ្នាក់លេខ ៧ |
| ០៩ | លោក **កៅ សិរិទ្ធ** | វរមន្ត្រី | ថ្នាក់លេខ ៧ |
| ១០ | លោក **សម សាមុត** | វរមន្ត្រី | ថ្នាក់លេខ ៧ |
| ១១ | លោក **សៀង ម៉ិនឌុង** | វរមន្ត្រី | ថ្នាក់លេខ ៧ |
| ១២ | លោក **កែវ គន្ធី** | វរមន្ត្រី | ថ្នាក់លេខ ៧ |
| ១៣ | លោក **អេង ហ៊ុន** | វរមន្ត្រី | ថ្នាក់លេខ ៨ |
| ១៤ | លោក **ជេត ណារ៉ែន** | វរមន្ត្រី | ថ្នាក់លេខ ៨ |
| ១៥ | លោក **កែរ ទិសិដ្ឋ** | វរមន្ត្រី | ថ្នាក់លេខ ១០ |
| ១៦ | លោក **សុក ជា** | វរមន្ត្រី | ថ្នាក់លេខ ១០ |
| ១៧ | លោក **ចេង ម៉ានិត** | វរមន្ត្រី | ថ្នាក់លេខ ១០ |
| ១៨ | លោក **ចាន់ រតនា** | វរមន្ត្រី | ថ្នាក់លេខ ១០ |
| ១៩ | លោក **អ៊ុច ហ៊ាង** | វរមន្ត្រី | ថ្នាក់លេខ ១០ |

**មាត្រា ២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ - កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** ១១៣ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើសុំរបស់ក្រសួងអប់រំផែ្ទ

## ស ំ រ េ ច

**មាត្រា១** : ត្រូវបានបំពាក់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជនចំនួន ០៩នាក់ ដែលបានបរិច្ចាគថវិកាជួយកសាងសមិទ្ធិផលនានា នៅក្នុងស្រុកអូររាំងឪ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោមនេះ

**ក_ មេដាយមាសស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោកឧកញ៉ា | **ប៉ែន ស៊ីផាន់** | ថវិកាចំនួន | ១២.៩៥០ ដុល្លារ |
| ២- លោក | **កុយ សុខខន់** | ថវិកាចំនួន | ១១.៥០០ ដុល្លារ |
| ៣- លោក | **យាវ គឹមហ៊ាន** | ថវិកាចំនួន | ១០.៥៤២ ដុល្លារ |
| ៤-លោកជំទាវ | **ឈុក ឈីម** | ថវិកាចំនួន | ១០.៨០០ ដុល្លារ |
| ៥-លោកជំទាវ | **សាន អារុណ** | ថវិកាចំនួន | ១០.០៧០ ដុល្លារ |

**ខ_ មេដាយប្រាក់ស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោក | **មិន នីម** | ថវិកាចំនួន | ៦.០០០ ដុល្លារ |

**គ_ មេដាយសំរឹទ្ធស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោក | **គីម សោម** | ថវិកាចំនួន | ៣.០២[illegible] ដុល្លារ |
| ២-ឧបាសក | **តេក សាខ** | ថវិកាចំនួន | ២.៣៥០ ដុល្លារ |
| ៣-លោក | **សាត ចន្ថា** | ថវិកាចំនួន | ២.១៥០ ដុល្លារ |

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិនា ឆ្នាំ២០០៤

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន ០៦រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាង ព្រះវិហារ នៅក្នុងវត្ត *កេររស្មី* ភូមិខ្នារកណ្តាល ឃុំខ្នាររង្គារ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដូចមានរាយព្រះនាម និង នាម ខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ **ម៉ូ ធី** ព្រះចៅអធិការ វត្ត*កេររស្មី* បច្ច័យចំនួន ១០.៤១០ ដុល្លារ

២-ព្រះតេជគុណ **ឈួន ចំរើន** ព្រះចៅអធិការវត្តពោធិព្រឹក្ស ហៅ វត្តខ្នារ បច្ច័យចំនួន ១០.០៤០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោក **ស៊ូ តាព** និង ភរិយា ទឹកប្រាក់ចំនួន ៥.៤២០ ដុល្លារ

២-លោក **គ្រួយ គីមឡុង** និង ភរិយា ទឹកប្រាក់ចំនួន ៥.២៤០ ដុល្លារ

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-លោកអាចារ្យ **ស្វាយ គីម** ទឹកប្រាក់ចំនួន ៤.៣២០ ដុល្លារ

២-លោកអាចារ្យ **ស្វាយ ស៊ីនឿន** ទឹកប្រាក់ចំនួន ៤.២៤០ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
156 - ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន*អង្គការសមាគម* និង សប្បុរសជនជប៉ុន ដែលបានផ្តល់ថវិកា ជួយសាងសង់អគារសិក្សា បំពាក់សម្ភារៈសិក្សា សាងសង់បង្គន់អនាម័យ និង អណ្តូងទឹកស្អាត ជូនសាលាបឋមសិក្សា តាមបណ្តាស្រុក នៃ ខេត្តកំពង់ធំ ដូចមានរាយនាម ខាងក្រោម :-

| | | |
|---|---|---|
| ១-***សមាគមស្ម័គ្រចិត្តសន្តិភាព ម៉ែយ៉ាឆ្គី*** | ប្រទេសជប៉ុន | ទឹកប្រាក់ ២៥.៣៨៥ ដុល្លារ |
| ២-***សមាគមស្ម័គ្រចិត្ត កាណេះ*** | ប្រទេសជប៉ុន | ទឹកប្រាក់ ១៦.៩៣៥.៦៥ ដុល្លារ |
| ៣-***អង្គការ Moralogy International Relief Committee*** | នៅប្រទេសជប៉ុន | ទឹកប្រាក់ ១៦.៨៦៩ ដុល្លារ |
| ៤-លោកស្រី ***កាស៊ិកូ កាមេតា*** | សប្បុរសជនជប៉ុន | ទឹកប្រាក់ ១៦.៨៦៩ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

**សំ រេ ច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន ១០រូប ដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាង ព្រះវិហារ និង សមិទ្ធផលនានា នៅក្នុងវត្ត *ត្រពាំងប្រាសាទ* ភូមិពាំងត្រពាំង ឃុំពេជ្រចង្វារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :-

**ក.មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **អ៊ុច ចំនួមុនី** | គង់នៅសហរដ្ឋអាមេរិក | បច្ច័យចំនួន | ៤៧.០០០ ដុល្លារ |
| ២-ព្រះតេជគុណ | **ឆាំល់ នែន** | ព្រះចៅអធិការវត្តត្រពាំងប្រាសាទ | បច្ច័យចំនួន | ៣០.០០០ ដុល្លារ |
| ៣-លោក | **គង់ សារេន** | សប្បុរសជន | ទឹកប្រាក់ចំនួន | ១១.០០០ ដុល្លារ |
| ៤-លោក | **ស៊ឹម សុផុន** | សប្បុរសជន | ទឹកប្រាក់ចំនួន | ១១.០០០ ដុល្លារ |
| ៥-លោក | **ពិន ថុក** | អាចារ្យវត្តត្រពាំងប្រាសាទ | ទឹកប្រាក់ចំនួន | ១១.០០០ ដុល្លារ |

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ភិក្ខុ | **មិត្ត សុផល** | គង់នៅវត្តត្រពាំងប្រាសាទ | ទឹកប្រាក់ចំនួន | ៨.០០០ ដុល្លារ |
| ២-លោក | **ភួន សិត** | រស់នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន | ៩.០០០ ដុល្លារ |

**គ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-លោក | **លីម សុិត** | ប្រធានគណៈកម្មការវត្តត្រពាំងប្រាសាទ | ទឹកប្រាក់ចំនួន | ៤.៥០០ ដុល្លារ |
| ២-លោក | **ទ្រេស អ៊ុល** | អនុប្រធានគណៈកម្មការវត្តត្រពាំងប្រាសាទ | ទឹកប្រាក់ចំនួន | ៤.៤០០ ដុល្លារ |
| ៣-លោក | **មាន់ សយ** | អាចារ្យរង វត្តត្រពាំងប្រាសាទ | ទឹកប្រាក់ចំនួន | ៣.២១០,២២ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
 ដូចក្នុងមាត្រា២ និងមាត្រា៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៧ រូប ដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគថវិកា ចូលរួមជួយកសាងព្រះវិហារ វត្ត*អង្គសិលាមុនី* ឃុំថ្មសរ ស្រុកបុទុមសាគរ ខេត្តកោះកុង ដូចមាន រាយនាមខាងក្រោមនេះ :-

**ក.មេដាយមាសស្ថាបនាជាតិ :**

-ឧកញ៉ា **លី យ៉ុងផាត់** ទឹកប្រាក់ចំនួន ១០.០០០ ដុល្លារ និង ៥៥០.០០០ បាត

**ខ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | **កុក ម៉េង** | ទឹកប្រាក់ចំនួន | ១.០០០ ដុល្លារ និង ២០.០០០ បាត |
| ២-លោក | **ហេង សាន** | ទឹកប្រាក់ចំនួន | ១៧៨.២៣៨ បាត |
| ៣-លោក | **អិក គួន** | ទឹកប្រាក់ចំនួន | ១៤៦.៥០០ បាត |
| ៤-លោក | **ឡាត់ ខ្មៀ** | ទឹកប្រាក់ចំនួន | ៥០.០០០ បាត |
| ៥-លោក | **លឹម លុច** | ទឹកប្រាក់ចំនួន | ១.៧០០ ដុល្លារ |
| ៦-លោកស្រី | **លឹម ឈ័រហ្វ** | ទឹកប្រាក់ចំនួន | ៦.៥០០.០០០ រៀល |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកោះកុង ត្រូវ អនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច ✓
157 -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៥ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

### សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ចំនួន ០១ គ្រឿង ជូនលោក **ខូន សំណាង** ជំនួយការទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ជូនសម្តេចនាយករដ្ឋមន្ត្រី សំរេចបានលទ្ធផលល្អប្រសើរ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

AKru

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខៈ ០៨៦ ប្រក.កសក

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យប្រើបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីអំពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- តាមសំណើរបស់នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានដាក់ឱ្យប្រើប្រាស់ នូវបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា ( Cambodia Specified Rubber ) ដូចមានឧបសម្ព័ន្ធភ្ជាប់មកជាមួយប្រកាសនេះ ។

**ប្រការ ២ :** បទដ្ឋានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ អាចកែប្រែក្នុងករណីមានការចាំបាច់ ។

**ប្រការ ៣ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :** អគ្គនាយកនៃក្រសួង អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានចំការកៅស៊ូ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានបុគ្គលិក និង អភិវឌ្ឍន៍ធនធានមនុស្ស នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និង អង្គភាពក្រោមឱវាទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលមានការពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៤

រដ្ឋមន្ត្រី

ច័ន្ទ សារុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ដូចប្រការ៤
- ឯកសារ -កាលប្បវត្តិ

ឧបសម្ព័ន្ធ ភ្ជាប់ប្រកាសលេខ ០៩៦ ប្រក.កសកចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៤ ។

# បទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា

# CAMBODIA SPECIFIED RUBBER (CSR)

ត្រូវបានកំណត់នូវបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជាថ្មីមួយ ដើម្បីធានាគុណភាពផលិតផលកៅស៊ូទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់ ។ ឈ្មោះសង្ខេបសម្រាប់យថាប្រភេទកៅស៊ូកម្ពុជាគឺ CSR (Cambodia Specified Rubber) ជំនួសឈ្មោះចាស់ CSK (*Caoutchouc Spécifié du Kampuchea*) ។ តាមបទដ្ឋាននេះកៅស៊ូធម្មជាតិកម្ពុជាដែលត្រូវបានកែច្នៃចេញពីទឹកជ័រ (Latex) និងជ័រកកធម្មជាតិ (Field grade material) ដូចជា ជ័រចាន ជ័រមុខ និងជ័រដី នឹងត្រូវបាន បែកជាថ្នាក់និងធ្វើតេស្តដោយហ្មត់ចត់ ហើយអ្វីដែលខុសពីស្តង់ដានេះពុំត្រូវបានអនុញ្ញាតឡើយ ។ ការកំណត់យថាប្រភេទសម្រាប់ថ្នាក់កៅស៊ូ (CSR) នីមួយៗត្រូវបានចែងនៅក្នុងចំណុចទី ៣ ។

## ១. លំដាប់ថ្នាក់ប្រភេទកៅស៊ូកម្ពុជា

ផលិតផលកៅស៊ូ CSR ក្នុងព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃនេះមានចំនួន ៥ ថ្នាក់ជាអាទិ៍ CSR 3L, CSR L, CSR 5, CSR 10 និង CSR 20 ។ កៅស៊ូថ្នាក់វីស្កូស៊ីធីថេរ (CSR CV) ក៏ត្រូវបានគ្រោងបន្ថែមទៅក្នុងថ្នាក់ទាំងនោះនៅថ្ងៃអនាគត ។

តារាង ១ : វត្ថុធាតុសម្រាប់ផលិតថ្នាក់កៅស៊ូ CSR

| វត្ថុធាតុ | ថ្នាក់កៅស៊ូ |
|---|---|
| ទឹកជ័រ (Latex) បង្កកដោយអាស៊ីត | CSR CV, CSR 3L, CSR L, CSR 5 |
| ជ័រកកធម្មជាតិ (Field grade material) | CSR 10, CSR 20 |

## ២. វិធីធ្វើតេស្ត

បទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា (CSR) ផ្តល់នូវភាពអាចផ្លាស់ប្តូរបាននៃការធ្វើតេស្តកៅស៊ូតាមស្តង់ដាអន្តរជាតិដែលអតិថិជនកំហត់ ។ បទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា (CSR) អាចធ្វើតេស្តតាម ISO Methods ឬតាម SMR Methods ។ ប៉ុន្តែការបោះពុម្ពផ្សាយនូវវិធីវិភាគចុងក្រោយបង្អស់នឹងត្រូវបានយកមកប្រើប្រាស់ ។

| **ប៉ារ៉ាម៉ែត្រដែលត្រូវធ្វើតេស្ត** | **ISO Method** | **SMR Method** |
|---|---|---|
| ១. អសុទ្ធភាព | ISO 249 | SMR Bull. No.7, B4 |
| ២. បំលាស់រូបដើម, $P_0$ | ISO 2007 | SMR Bull. No.7, B8 |
| ៣. សន្ទស្សន៍នៃការរក្សាបំលាស់រូប, PRI | ISO 2930 | SMR Bull. No.7, B8 |

| | | |
|---|---|---|
| ៤. អាសូត | ISO 1656 | SMR Bull. No.7. B7 |
| ៥. សារធាតុហើរ | ISO 248 | SMR Bull. No.7. B5 |
| ៦. ផេះ | ISO 247 | SMR Bull. No.7. B6 |
| ៧. សន្ទស្សន៍ពណ៌ Lovibond (សម្រាប់ថ្នាក់ L) | ISO 4660 | SMR Bull. No.7. B10 |
| ៨. វិស្កូស៊ីធីមូនី (M.V) | ISO 289 | SMR Bull. No.7. B9 |

## ៣. យថាប្រភេទ

លំដាប់ថ្នាក់កៅស៊ូ CSR ត្រូវកំណត់តាមយថាប្រភេទដូចមានក្នុងតារាងខាងក្រោម :

តារាង ២ : បទដ្ឋានកំណត់យថាប្រភេទកៅស៊ូ CSR

| ប៉ារ៉ាម៉ែត្រ | CSR CV | CSR 3L | CSR L | CSR 5 | CSR 10 | CSR 20 |
|---|---|---|---|---|---|---|
| | បៃតង | បៃតង | បៃតង | បៃតង | ត្នោត | ក្រហម |
| | ទឹកជ័រ (Latex) | | | | ជ័រកកធម្មជាតិ (Field grade material) | |
| អសុទ្ធភាព (% ទម្ងន់ អតិបរមា) | 0,05 | 0,03 | 0,05 | 0,05 | 0,1 | 0,2 |
| បំលាស់រូបដើម, $P_0$ (អប្បបរមា) | - | 35 | 30 | 30 | 30 | 30 |
| សន្ទស្សន៍នៃការរក្សាបំលាស់រូប, PRI (% អប្បបរមា) | 60 | 60 | 60 | 60 | 50 | 40 |
| អាសូត (% ទម្ងន់ អតិបរមា) | 0,6 | 0,6 | 0,6 | 0,6 | 0,6 | 0,6 |
| សារធាតុហើរ (% ទម្ងន់ អតិបរមា) | 0,8 | 0,8 | 0,8 | 0,8 | 0,8 | 0,8 |
| ផេះ (% ទម្ងន់ អតិបរមា) | 0,6 | 0,5 | 0,6 | 0,6 | 0,75 | 1,0 |
| សន្ទស្សន៍ពណ៌ (អតិបរមា) | - | 6<br>2 * | 6 | - | - | - |
| វិស្កូស៊ីធីមូនី ML(1'+4')100 C | 60 ± 5 ** | - | - | - | - | - |

* ភាពខុសគ្នាអតិបរមារវាងសន្ទស្សន៍ពណ៌របស់គំរូវិភាគនីមួយៗ ។

** វិស្កូស៊ីធីរបស់កៅស៊ូត្រូវកំណត់ឡើងដោយផលិតករ ដើម្បីបំពេញតាមតម្រូវការរបស់អតិថិជន ។

## ៤. ទម្ងន់ ទំហំ និង ការវេចខ្ចប់

តារាង ៣ : ទម្ងន់ ទំហំ និង ការវេចខ្ចប់

| | |
|---|---|
| ទម្ងន់ដុំកៅស៊ូ | ៣៣.៣ គីឡូក្រាម ± ០.១ គីឡូក្រាម |
| ទំហំដុំកៅស៊ូ | ៦៧០ ម.ម. × ៣៣០ ម.ម. × ១៧០ ម.ម. |
| ទម្ងន់ដុំកៅស៊ូសុទ្ធក្នុងកែសប៉ាឡែត | ១២០០ គីឡូក្រាម |
| ទម្ងន់ដុំកៅស៊ូសុទ្ធរួមទាំងកែសប៉ាឡែត | ១៣០០ គីឡូក្រាម |
| ថង់ប្រកដុំកៅស៊ូ | ថង់ប៉ូលីអេទីឡែនដង់ស៊ីតេទាប (LDPE)<br>កម្រាស់ ០.០៣ - ០.០៥ ម.ម.<br>កម្រិតរលាយ ១០៥ °C (អតិបរមា) |

*** និមិត្តសញ្ញាសំគាល់ផ្សេងៗទៀតប្រែប្រួលទៅតាមសហគ្រាសផលិតនីមួយៗ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ: ០៩៩ ប្រក.កសក.បុ

# ប្រកាស

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញ ព្រះរាជក្រមលេខ ០៦ នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល .
- បានឃើញ ព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ .
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៨០២ / ០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ .
- បានឃើញ អនុក្រឹត្យ លេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ .
- បានឃើញ អនុក្រឹត្យ លេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ .
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ .
- បានឃើញលិខិតលេខ លេខ ០៣៥ មស.គត ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៤ របស់រដ្ឋលេខាធិការ-ដ្ឋានមុខងារសាធារណៈ ស្តីពីការឯកភាពជាគោលការណ៍តែងតាំងមន្ត្រីរដ្ឋបាលព្រៃឈើ

## ស ម្រេ ច

**ប្រការ ១** : ត្រូវបានតែងតាំងមន្ត្រីរដ្ឋបាលព្រៃឈើ ជានាយ នាយរង ផ្នែករដ្ឋបាលព្រៃឈើ ដូចមានរាយនាមខាងក្រោម:

១-ផ្នែករដ្ឋបាលព្រៃឈើលំផាត់:

| | | | |
|---|---|---|---|
| ១- លោក | ឡេង | យុគ | ជានាយផ្នែក រដ្ឋបាលព្រៃឈើលំផាត់ |
| ២- លោក | មូល | សាំវ៉ាង | ជានាយរង |
| ៣- លោក | ហេង | ស៊ាងហុង | ជានាយរង |

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B.V.D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352. Fax : (855) 23 - 217 320

២-ផ្នែករដ្ឋបាលព្រៃឈើបកែវ:

| | | | |
|---|---|---|---|
| ១- លោក | ប៉ាក់វង្ស | សុមេធី | ជានាយផ្នែក រដ្ឋបាលព្រៃឈើបកែវ |
| ២- លោក | កែវ | វុធ | ជានាយរង |
| ៣- លោក | ឌន់ | វីរៈភាព | ជានាយរង |

៣-ផ្នែករដ្ឋបាលព្រៃឈើវើនសៃ:

| | | | |
|---|---|---|---|
| ១- លោក | សៅ | វ៉ាន្នី | ជានាយផ្នែក រដ្ឋបាលព្រៃឈើវើនសៃ |
| ២- លោក | ហោ | ណារិទ្ធ | ជានាយរង |
| ៣- លោក | ប៊ាង | ចំរើន | ជានាយរង |

៤-ផ្នែករដ្ឋបាលព្រៃឈើថាឡាបរិវ៉ាត់:

| | | | |
|---|---|---|---|
| ១- លោក | ទៀង | ដារិទ្យ | ជានាយផ្នែក រដ្ឋបាលព្រៃឈើថាឡាបរិវ៉ាត់ |
| ២- លោក | ម៉ី | ម៉េងលីម | ជានាយរង |
| ៣- លោក | សោម | ឧទ្ធរិទ្ធ | ជានាយរង |
| ៤- លោក | ស៊ី | សុវត្ថា | ជានាយរង |

៥-ផ្នែករដ្ឋបាលព្រៃឈើស្ទឹងត្រែង:

| | | | |
|---|---|---|---|
| ១- លោក | វង | សុក្រសីរ៍ | ជានាយផ្នែក រដ្ឋបាលព្រៃឈើស្ទឹងត្រែង |
| ២- លោក | លី | គន | ជានាយរង |
| ៣- លោក | គាំ | សីហា | ជានាយរង |
| ៤- លោក | ឌង | ខេមរិទ្ធ | ជានាយរង |

៦-ផ្នែករដ្ឋបាលព្រៃឈើសៀមប៉ាង:

| | | | |
|---|---|---|---|
| ១- លោក | ងួន | សុខឃីម | ជានាយផ្នែក រដ្ឋបាលព្រៃឈើសៀមប៉ាង |
| ២- លោក | ខែក | យ៉ូ | ជានាយរង |
| ៣- លោក | ម៉ុក | សុមុនី | ជានាយរង |

៧-ផ្នែករដ្ឋបាលព្រៃឈើកែវសីមា:

| | | | |
|---|---|---|---|
| ១- លោក | ពេជ | ណារ៉ុង | ជានាយផ្នែក រដ្ឋបាលព្រៃឈើកែវសីមា |
| ២- លោក | ឈួន | សេរីវឌ្ឍន៍ | ជានាយរង |
| ៣- លោក | ខៀវ | រិទ្ធិភ័ណ្ឌ | ជានាយរង |

៨-ផ្នែករដ្ឋបាលព្រៃឈើកោះញែក:

| | | | |
|---|---|---|---|
| ១- លោក | សុខ | ភិត | ជានាយផ្នែក រដ្ឋបាលព្រៃឈើកោះញែក |
| ២- លោក | យុង | ផល្លី | ជានាយរង |
| ៣- លោក | ព្រុំ | សុវណ្ណា | ជានាយរង |

៩-ផ្នែករដ្ឋបាលព្រៃឈើសែនមនោរម្យ:

| | | | |
|---|---|---|---|
| ១- លោក | ប៊ូ | សុខុម | ជានាយផ្នែក រដ្ឋបាលព្រៃឈើសែនមនោរម្យ |
| ២- លោក | ទ្រី | វណ្ណថន | ជានាយរង |

៣- លោក រ៉ុំ វណ្ណសុភ: ជានាយរងផ្នែក រដ្ឋបាលព្រៃឈើសែនមនោរម្យ

១០-ផ្នែករដ្ឋបាលព្រៃឈើឆ្លូង:

១- លោក ថោង វ៉ាន់វីរ៉ាវុឌ្ឍី ជានាយផ្នែក រដ្ឋបាលព្រៃឈើឆ្លូង

២- លោក រ័ត្ន វិចិត្រ ជានាយរង

៣- លោក ហួត គង់ ជានាយរង

៤- លោក ប្រាក់ សំបូរ ជានាយរង

៥- លោក ព្រាប សុទ្ធារ៉ា ជានាយរង

១១-ផ្នែករដ្ឋបាលព្រៃឈើព្រែកប្រសព្វ:

១- លោក ស៊ីវ វណ្ណៈ ជានាយផ្នែក រដ្ឋបាលព្រៃឈើព្រែកប្រសព្វ

២- លោក អ៊ុយ ស្រី ជានាយរង

៣- លោក ស៊ិន សំណាង ជានាយរង

៤- លោក វណ្ណ សារុធ ជានាយរង

១២-ផ្នែករដ្ឋបាលព្រៃឈើក្រចេះ:

១- លោក សិទ្ធិ សំណាង ជានាយផ្នែក រដ្ឋបាលព្រៃឈើក្រចេះ

២- លោក រឿង សុជាត ជានាយរង

៣- លោក ថា រិទ្ធ ជានាយរង

៤- លោក អ៊ឹង ស៊ីណាង ជានាយរង

១៣-ផ្នែករដ្ឋបាលព្រៃឈើកំពង់ចាមត្រើយស្តាំ:

១- លោក កែវ ដាឌីធី ជានាយផ្នែក រដ្ឋបាលព្រៃឈើកំពង់ចាមត្រើយស្តាំ

២- លោក សឿង សុផន ជានាយរង

៣- លោក រស់ សារ័ត្ន ជានាយរង

៤- លោក ញ៉ែម តារារិទ្ធ ជានាយរង

១៤-ផ្នែករដ្ឋបាលព្រៃឈើកំពង់ចាមត្រើយឆ្វេង:

១- លោក អ៊ីវ ឯកសារិតី ជានាយផ្នែក រដ្ឋបាលព្រៃឈើកំពង់ចាមត្រើយឆ្វេង

២- លោក ហុង សុខ ជានាយរង

៣- លោក សូ ដារី ជានាយរង

៤- លោក ស ហួត ជានាយរង

៥- លោក ឈាន ងន់ហុង ជានាយរង

១៥-ផ្នែករដ្ឋបាលព្រៃឈើមេមត់:

១- លោក ដេត សីលា ជានាយផ្នែក រដ្ឋបាលព្រៃឈើមេមត់

២- លោក ហ៊ី តាំប៉ា ជានាយរង

៣- លោក គង់ វុធថា ជានាយរង

៤- លោក ឈាង ជាន ជានាយរង

៥- លោក ជុយ សុខឃាង ជានាយរង

១៦-ផ្នែករដ្ឋបាលព្រៃឈើព្រៃវែងៈ

| | | | | |
|---|---|---|---|---|
| ១ | លោក | ផល | មុនី | ជានាយផ្នែក រដ្ឋបាលព្រៃឈើព្រៃវែង |
| ២- | លោក | ស្រេង | សុខខេង | ជានាយរង |
| ៣- | លោក | ហេង | ត្រីស្នា | ជានាយរង |

១៧-ផ្នែករដ្ឋបាលព្រៃឈើស្វាយរៀងៈ

| | | | | |
|---|---|---|---|---|
| ១- | លោក | ឈួន | ចាន់វុឌ្ឍី | ជានាយផ្នែក រដ្ឋបាលព្រៃឈើស្វាយរៀង |
| ២- | លោក | យក់ | ប៊ុនធាន | ជានាយរង |
| ៣- | លោក | វ៉ាន់ | សារ៉េត | ជានាយរង |

១៨-ផ្នែករដ្ឋបាលព្រៃឈើជីក្រែងៈ

| | | | | |
|---|---|---|---|---|
| ១- | លោក | សូ | ហៃ | ជានាយផ្នែក រដ្ឋបាលព្រៃឈើជីក្រែង |
| ២- | លោក | ជុក | សំអាត | ជានាយរង |
| ៣- | លោក | ឃី | ឧត្តរ៉ា | ជានាយរង |

១៩-ផ្នែករដ្ឋបាលព្រៃឈើបន្ទាយស្រីៈ

| | | | | |
|---|---|---|---|---|
| ១- | លោក | យឹម | ប៉ាន់ | ជានាយផ្នែក រដ្ឋបាលព្រៃឈើបន្ទាយស្រី |
| ២- | លោក | សេង | វឿត | ជានាយរង |
| ៣- | លោក | ចាប | ចាន់ថុល | ជានាយរង |
| ៤- | លោក | ហាស | សុផុន | ជានាយរង |
| ៥- | លោក | ពាំង | ចាន់សែម៉ា | ជានាយរង |

២០-ផ្នែករដ្ឋបាលព្រៃឈើក្រឡាញ់ៈ

| | | | | |
|---|---|---|---|---|
| ១- | លោក | ឯក | មុនី | ជានាយផ្នែក រដ្ឋបាលព្រៃឈើក្រឡាញ់ |
| ២- | លោក | សូ | ជល្លា | ជានាយរង |
| ៣- | លោក | អ៊ុង | វុធារ៉ា | ជានាយរង |
| ៤- | លោក | ប្រាក់ | ប៊ុន្នី | ជានាយរង |

២១-ផ្នែករដ្ឋបាលព្រៃឈើព្រះនេត្រព្រះ :

| | | | | |
|---|---|---|---|---|
| ១- | លោក | សាន់ | គឹមឃាង | ជានាយផ្នែក រដ្ឋបាលព្រៃឈើព្រះនេត្រព្រះ |
| ២- | លោក | គាន | វ៉ាន់ថា | ជានាយរង |
| ៣- | លោក | ម៉ៅ | សារី | ជានាយរង |

២២-ផ្នែករដ្ឋបាលព្រៃឈើថ្មពួកៈ

| | | | | |
|---|---|---|---|---|
| ១- | លោក | សួរ | សារ៉ែម | ជានាយផ្នែក រដ្ឋបាលព្រៃឈើថ្មពួក |
| ២- | លោក | ទិត្យ | ណារា | ជានាយរង |
| ៣- | លោក | ង៉ែត | ភូ | ជានាយរង |

២៣-ផ្នែករដ្ឋបាលព្រៃឈើបន្ទាយអំពិលៈ

| | | | | |
|---|---|---|---|---|
| ១- | លោក | ហៃ | សម្បត្តិ | ជានាយផ្នែក រដ្ឋបាលព្រៃឈើបន្ទាយអំពិល ៥/ |

| | | | |
|---|---|---|---|
| ២- លោក | អ៊ូ | វណ្ណារ៉េត | ជានាយករងផ្នែក រដ្ឋបាលព្រៃឈើបន្ទាយអំពិល |
| ៣- លោក | ស៊ិន | អ៊ីណោបុត្រ | ជានាយករង |

២៤-ផ្នែករដ្ឋបាលព្រៃឈើសំរោង:

| | | | |
|---|---|---|---|
| ១- លោក | ឃុន | សុភា | ជានាយផ្នែក រដ្ឋបាលព្រៃឈើសំរោង |
| ២- លោក | នៃ | ឈឿង | ជានាយរង |
| ៣- លោក | ទួន | ម៉ានិល | ជានាយរង |

២៥-ផ្នែករដ្ឋបាលព្រៃឈើអន្លង់វែង:

| | | | |
|---|---|---|---|
| ១- លោក | ប៉ែន | វិសេស | ជានាយផ្នែក រដ្ឋបាលព្រៃឈើអន្លង់វែង |
| ២- លោក | ឡឹក | ហេង | ជានាយរង |
| ៣- លោក | ឡាយ | ផល្លា | ជានាយរង |

២៦-ផ្នែករដ្ឋបាលព្រៃឈើនែប:

| | | | |
|---|---|---|---|
| ១- លោក | ឆាយ | ណារ៉េត | ជានាយផ្នែក រដ្ឋបាលព្រៃឈើនែប |
| ២- លោក | ស្រី | សោភ័ណ | ជានាយរង |
| ៣- លោក | តុង | យី | ជានាយរង |

២៧-ផ្នែករដ្ឋបាលព្រៃឈើរវៀង:

| | | | |
|---|---|---|---|
| ១- លោក | ហែម | សារ៉ាត | ជានាយផ្នែក រដ្ឋបាលព្រៃឈើរវៀង |
| ២- លោក | គង់ | ប៊ុនហួន | ជានាយរង |
| ៣- លោក | ចាន់ | វិទ្យា | ជានាយរង |

២៨-ផ្នែករដ្ឋបាលព្រៃឈើត្បែងមានជ័យ:

| | | | |
|---|---|---|---|
| ១- លោក | មុនី | វីរៈ | ជានាយផ្នែក រដ្ឋបាលព្រៃឈើត្បែងមានជ័យ |
| ២- លោក | ហ៊ុអ | ស៊ីរ៉ន | ជានាយរង |
| ៣- លោក | សូ | សុវិទ្យា | ជានាយរង |
| ៤- លោក | សុទ្ធ | ម៉ារី | ជានាយរង |

២៩-ផ្នែករដ្ឋបាលព្រៃឈើជាំក្សាន្ត:

| | | | |
|---|---|---|---|
| ១- លោក | តាន់ | សេដ្ឋា | ជានាយផ្នែក រដ្ឋបាលព្រៃឈើជាំក្សាន្ត |
| ២- លោក | វង្ស | វិស្សិត | ជានាយរង |
| ៣- លោក | នូ | ដារ៉ា | ជានាយរង |

៣០-ផ្នែករដ្ឋបាលព្រៃឈើកំពង់ថ្ម:

| | | | |
|---|---|---|---|
| ១- លោក | ម៉ី | វីរៈ | ជានាយផ្នែក រដ្ឋបាលព្រៃឈើកំពង់ថ្ម |
| ២- លោក | សុខ | វណ្ណារ៉េន | ជានាយរង |
| ៣- លោក | គៀត | សត្ថារិទ្ធ | ជានាយរង |
| ៤- លោក | ឯម | សុគន្ធ | ជានាយរង |

៣១-ផ្នែករដ្ឋបាលព្រៃឈើសណ្ដាន់:

| | | | |
|---|---|---|---|
| ១- លោក | ជា | ផល្លី | ជានាយផ្នែក រដ្ឋបាលព្រៃឈើសណ្ដាន់ |

៧

២ លោក ឃុន ប៊ុនហេង ជានាយរងផ្នែក រដ្ឋបាលព្រៃឈើសណ្ដាន់

៣ លោក អ៊ុន បុត្ត ជានាយរង

៤ លោក ឃិន វិណ្ណៈ ជានាយរង

៣២-ផ្នែករដ្ឋបាលព្រៃឈើស្ទោងៈ

១ លោក អ៊ុត ភូក្រា ជានាយផ្នែក រដ្ឋបាលព្រៃឈើស្ទោង

២- លោក ឡុញ ប៊ុណ្ណារិទ្ធ ជានាយរង

៣- លោក សេង ភក្តី ជានាយរង

៤- លោក ម៉ក់ បញ្ញា ជានាយរង

៣៣-ផ្នែករដ្ឋបាលព្រៃឈើកណ្ដាលៈ

១- លោក យ៉ុន យុរិទ្ធិ ជានាយផ្នែក រដ្ឋបាលព្រៃឈើកណ្ដាល

២- លោក ពូ វិណ្ណរិទ្ធិ ជានាយរង

៣- លោក អ៊ូ សេរី ជានាយរង

៤- លោក ចេង សុផេង ជានាយរង

៥- លោក សេង កុសល ជានាយរង

៣៤-ផ្នែករដ្ឋបាលព្រៃឈើបសេដ្ឋៈ

១- លោក ពែរេច ភីន ជានាយផ្នែក រដ្ឋបាលព្រៃឈើបសេដ្ឋ

២- លោក វី សំណាង ជានាយរង

៣- លោក ឡុង វិឡូនៈ ជានាយរង

៣៥-ផ្នែករដ្ឋបាលព្រៃឈើឧិរ៉ាល់ៈ

១- លោក អ៊ុក ហ៊ុត ជានាយផ្នែក រដ្ឋបាលព្រៃឈើឱរ៉ាល់

២- លោក អ៊ូ សោភ័ឿន ជានាយរង

៣- លោក ប៊ុល ចាន់ថា ជានាយរង

៤- លោក ងួន ប៊ុណ្ណារ៉ា ជានាយរង

៣៦-ផ្នែករដ្ឋបាលព្រៃឈើកំពង់ស្ពឺ ៈ

១- លោក រត្ន័ សុវណ្ណារ៉ា ជានាយផ្នែក រដ្ឋបាលព្រៃឈើកំពង់ស្ពឺ

២- លោក ហង់ វិណ្ណថន ជានាយរង

៣- លោក គ្រួច កុសល ជានាយរង

៤- លោក អ៊ិត សោម ជានាយរង

៣៧-ផ្នែករដ្ឋបាលព្រៃឈើកំពង់ត្រឡាចៈ

១- លោក បែន បុល្លីណា ជានាយផ្នែក រដ្ឋបាលព្រៃឈើកំពង់ត្រឡាច

២- លោក ចិន ប៊ុនឆាត ជានាយរង

៣- លោក ឈឹន កុសល ជានាយរង

៤- លោក បេក ដារ៉ា ជានាយរង

៣៨-ផ្នែករដ្ឋបាលព្រៃឈើកំពង់ឆ្នាំង:

១- លោក ឆោះ ភូរិទ្ធ ជានាយផ្នែក រដ្ឋបាលព្រៃឈើកំពង់ឆ្នាំង
២- លោក កង គឹមលី ជានាយរង
៣- លោក អ៊ុក សោភ៉ា ជានាយរង

៣៩-ផ្នែករដ្ឋបាលព្រៃឈើរមាស:

១- លោក ម៉ន វុទ្ធី ជានាយផ្នែក រដ្ឋបាលព្រៃឈើរមាស
២- លោក ហុង សុជាតិ ជានាយរង
៣- លោក ច័ន្ទ វណ្ណកេត ជានាយរង

៤០-ផ្នែករដ្ឋបាលព្រៃឈើវាលវែង:

១- លោក គឹម ណាក់ា ជានាយផ្នែក រដ្ឋបាលព្រៃឈើវាលវែង
២- លោក នង ច័ន្ទដា ជានាយរង
៣- លោក ជា គឹមសែ ជានាយរង

៤១-ផ្នែករដ្ឋបាលព្រៃឈើក្រវ៉ាញ:

១- លោក ជា ហួត ជានាយផ្នែក រដ្ឋបាលព្រៃឈើក្រវ៉ាញ
២- លោក ម៉ៅ បរិមិទ្ធ ជានាយរង
៣- លោក សុខ សុខុន ជានាយរង

៤២-ផ្នែករដ្ឋបាលព្រៃឈើក្រគរ:

១- លោក អ៊ុំ សុផា ជានាយផ្នែក រដ្ឋបាលព្រៃឈើក្រគរ
២- លោក គឹម ចេត្តារី ជានាយរង
៣- លោក ហួត ប៊ុនណុល ជានាយរង

៤៣-ផ្នែករដ្ឋបាលព្រៃឈើមោងឫស្សី:

១- លោក ទូច ប៉េងហួរ ជានាយផ្នែក រដ្ឋបាលព្រៃឈើមោងឫស្សី
២- លោក អ៊ុំ វីរៈ ជានាយរង
៣- លោក សួន ធីរស់ ជានាយរង

៤៤-ផ្នែករដ្ឋបាលព្រៃឈើបាត់ដំបង:

១- លោក ចាន់ សុត្ថា ជានាយផ្នែក រដ្ឋបាលព្រៃឈើបាត់ដំបង
២- លោក ប៉េង មុី ជានាយរង
៣- លោក ពិត ភារក្ស ជានាយរង

៤៥-ផ្នែករដ្ឋបាលព្រៃឈើរតនមណ្ឌល:

១- លោក អ៊ុន អួន នាយផ្នែក រដ្ឋបាលព្រៃឈើរតនមណ្ឌល
២- លោក ឡុង សុគន្ធ ជានាយរង
៣- លោក មាស ប៊ុនឡាប ជានាយរង

៤៦-ផ្នែករដ្ឋបាលព្រៃឈើបវេល:

១- លោក ឱម វីរៈ ជានាយផ្នែក រដ្ឋបាលព្រៃឈើបវេល

២- លោក ទូច អូន ជានាយរងផ្នែក រដ្ឋបាលព្រៃឈើសំរោងទង
៣- លោក គ្រុយ ទីរ៉េង ជានាយរង
៤- លោក កត បូរ៉ាន់ ជានាយរង

៤៧-ផ្នែករដ្ឋបាលព្រៃឈើប៉ៃលិនៈ

១- លោក ចាយ រដ្ឋា ជានាយផ្នែក រដ្ឋបាលព្រៃឈើប៉ៃលិន
២- លោក ហៃម សុជាត ជានាយរង
៣- លោក ពារ គីមហេង ជានាយរង

៤៨-ផ្នែករដ្ឋបាលព្រៃឈើដងទង់ៈ

១- លោក ប៊ុន រ៉េត ជានាយផ្នែក រដ្ឋបាលព្រៃឈើដងទង់
២- លោក ប៊ុង មោរ៉ា ជានាយរង
៣- លោក ជិន តារ៉ា ជានាយរង

៤៩-ផ្នែករដ្ឋបាលព្រៃឈើអណ្ដូងទឹកៈ

១ លោក សាយ សាយឿន ជានាយផ្នែក រដ្ឋបាលព្រៃឈើអណ្ដូងទឹក
២- លោក យាវ ឈុនឡាក់ ជានាយរង
៣- លោក ចេង រដ្ឋា ជានាយរង

៥០-ផ្នែករដ្ឋបាលព្រៃឈើស្រែអំបិលៈ

១- លោក ជួន សារ៉ា ជានាយផ្នែក រដ្ឋបាលព្រៃឈើស្រែអំបិល
២- លោក ជ រ៉ាងលី ជានាយរង
៣- លោក តុង សែ ជានាយរង
៤- លោក មេច សាត ជានាយរង

៥១-ផ្នែករដ្ឋបាលព្រៃឈើព្រែមង់ៈ

១- លោក ឌី សុភី ជានាយផ្នែក រដ្ឋបាលព្រៃឈើព្រែមង់
២- លោក វីម វណ្ណារ៉ាក់ ជានាយរង
៣- លោក ម៉ូវ សិរីវណ្ណា ជានាយរង

៥២-ផ្នែករដ្ឋបាលព្រៃឈើស្ទឹងហាវៈ

១- លោក ចាន់ សារិទ្ធ ជានាយផ្នែក រដ្ឋបាលព្រៃឈើស្ទឹងហាវ
២- លោក អ៊ី ម៉េងលាង ជានាយរង
៣- លោក ម៉ុក ណារិន ជានាយរង

៥៣-ផ្នែករដ្ឋបាលព្រៃឈើតាកែវៈ

១- លោក ញ៉ឹក ស៊ុនណារី ជានាយផ្នែក រដ្ឋបាលព្រៃឈើតាកែវ
២- លោក កែវ សេងគ្រី ជានាយរង
៣- លោក ហ៊ួត សារឿន ជានាយរង

៥៤-ផ្នែករដ្ឋបាលព្រៃឈើឈូកៈ

១- លោក ជុំ សុវត្ថា ជានាយផ្នែក រដ្ឋបាលព្រៃឈើឈូក

២- លោក ថោង សារី ជានាយរងផ្នែក រដ្ឋបាលព្រៃឈើឈូក

៣- លោក ទន់ ផាន ជានាយរង

៥៥-ផ្នែករដ្ឋបាលព្រៃឈើកែប:

១- លោក ឃាង បុរីម៉ា ជានាយផ្នែក រដ្ឋបាលព្រៃឈើកែប

២- លោក លីម សៀម ជានាយរង

៣- លោក សេង ប៊ុនណាត ជានាយរង

**ប្រការ ២** : ប្រកាសទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីជន ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៤

រដ្ឋមន្ត្រី

ច័ន្ទ សារុន

**កន្លែងទទួល**

- ទីស្តីការ គណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង

" ដើម្បីជូនជ្រាប "

- គ្រប់អធិការដ្ឋានរដ្ឋបាលព្រៃឈើ / ខណ្ឌរដ្ឋបាលព្រៃឈើ
- ដូចមានក្នុងប្រការ ៣

" ដើម្បីអនុវត្ត "

- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០៩០ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបន្ថែមសមាជិកនៅក្នុងក្រុមប្រតិបត្តិសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញឯកសារចក្ខុវិស័យនិងផែនការសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុពីឆ្នាំ២០០១-២០១០ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០១

-បានឃើញស្មារតីនៃកិច្ចចរចាររវាងតំណាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០១

-បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០១

-បានឃើញប្រកាសលេខ៥២១ សហវ.វស ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រតិបត្តិសំរាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

# សំរេច

**ប្រការ១:** បន្ថែមសមាជិក០២រូបទៅក្នុងក្រុមប្រតិបត្តិ (Task Force) ប្រចាំនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរាប់កម្មវិធីអភិវឌ្ឍវិស័យហិរញ្ញវត្ថុ (Financial Sector Development Program, ADB Loan No 1859-CAM (SF) ) ។ សមាសភាពបន្ថែមក្នុងក្រុមប្រតិបត្តិនេះមានដូចតទៅ:

| | | |
|---|---|---|
| ១ លោកស្រី ស៊ុន ណោលី | ប្រធានការិយាល័យគ្រប់គ្រងបំណុល | សមាជិក |
| ២-លោកស្រី រ៉ិន ខែ | អនុប្រធានការិយាល័យគ្រប់គ្រងបំណុល | សមាជិក |

**ប្រការ២:** អគ្គលេខាធិការ ខុទ្ទកាល័យ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុព្រមទាំងសាមីខ្លួនដូចប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះឱ្យបានប្រសិទ្ធិភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ [illegible] ឆ្នាំ២០០៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

ចំលងជូន:

-ធនាគារជាតិនៃកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៧១ សហវ.ប្រក

# ប្រកាស

## ស្តីពីការបង្កើតគណៈកម្មាធិការ
## សំរាប់កិច្ចសហប្រតិបត្តិការវិស័យហិរញ្ញវត្ថុរវាង កម្ពុជា និង ជប៉ុន
## របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឥស្សរជនជាអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការងារចាំបាច់របស់ក្រសួង

# សំ រេ ច

ប្រការ ១: បង្កើតគណៈកម្មាធិការមួយសំរាប់កិច្ចសហប្រតិបត្តិការវិស័យហិរញ្ញវត្ថុ រវាង កម្ពុជា និង ជប៉ុន របស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានសមាសភាពដូចតទៅ:

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម ចិន ឃន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានធនាគារជាតិ | អនុប្រធាន |
| ៣. លោក ម៉ី ទារ៉ិន | ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ៤. លោក នួច ឡេង | ប្រធាននាយកដ្ឋានថវិកានិយកម្ម និង ហិរញ្ញកិច្ច | សមាជិក |
| ៥. លោក ហ៊ីង សុខណ្ណ | អនុប្រធានទី ១ ធនាគារជាតិ | សមាជិក |
| ៦. លោក អៀង ស៊ុនលី | អនុប្រធានទី ១ នាយកដ្ឋានថវិកានិយកម្ម និង ហិរញ្ញកិច្ច | សមាជិក |
| ៧. លោក លី សែ | អនុប្រធានទី ១ នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាន | សមាជិក |
| ៨. លោក ម៉ិញ ចាន់កុសល | អនុប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ៩. លោក រស់ សីលវ៉ា | អនុប្រធានអង្គភាពផែនការនិយកម្ម និង តាមដានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១០. លោក ហាច រតនៈ | អនុប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាន | សមាជិក |

ប្រការ ២: គណៈកម្មាធិការនេះ មានភារៈកិច្ចទទួលអនុវត្តកិច្ចសហប្រតិបត្តិការរួមលើវិស័យហិរញ្ញវត្ថុ ជាមួយនឹង គណៈកម្មាធិការទទួលបន្ទុកកិច្ចសហប្រតិបត្តិការវិស័យហិរញ្ញវត្ថុរបស់ជប៉ុន ។

ប្រការ ៣: អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ មីនា ឆ្នាំ ២០០៤

គាត ឈន់

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  «ដើម្បីជូនជ្រាប»
- ដូចប្រការ ៣
- កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០២០ សហវ.ពន

# ប្រកាស
## ស្ដីពី
## ការបំពេញបន្ថែមលើការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៣

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែមិនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្ដីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
- បានឃើញប្រកាសលេខ ០០៤ ប្រក/សហវ/ពជ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០១ ស្ដីពីការផ្ដល់រង្វាន់ជូនអង្គភាពពន្ធដារ

- បានឃើញប្រកាសលេខ ២៨៧ សហវ/ពដ ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០៣ ស្តីពីការបែងចែកប្រាក់រង្វាន់របស អង្គភាពពន្ធដារ
- បានឃើញប្រកាសលេខ ៨៨៦ សហវ/ពដ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០០៣ ស្តីពីការប្រមូលពន្ធលើ មធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០០៣
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ ឆ្នាំ២០០៣

## សំរេច

**ប្រការ ១** : ចាប់ពីថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០០៤តទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យជាកពិន័យចំនួន មួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំង ឡាយណាដែលមិនបានមកបង់ពន្ធសំរាប់ឆ្នាំ២០០៣ ដូចបានកំណត់ក្នុងប្រការ ១ នៃប្រកាសលេខ ៨៨៦ សហវ.ពដ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០០៣ ។

ប្រាក់ពិន័យដែលទទួលបានមកអំពីការពិន័យលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ត្រូវ បានអនុញ្ញាតឱ្យបែងចែកដូចតទៅ :

១-ប្រាក់ពិន័យដែលទទួលបានក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ (នៅទីចំណោតនានា) ដែលមាន សហការរវាងមន្ត្រីពន្ធដារ និងមន្ត្រីមានសមត្ថកិច្ចដែលបានចូលរួម ត្រូវបានអនុញ្ញាតឱ្យដកចំនួន ៣៥% (សាមសិបប្រាំភាគរយ) លើប្រាក់ដែលពិន័យបាន សំរាប់ប្រើប្រាស់ជាប្រាក់រង្វាន់ ដោយត្រូវបែងចែក ដូចតទៅ :

- ៦០% នៃប្រាក់រង្វាន់ សំរាប់ចែកជូនសមាជិកនៃក្រុមប្រតិបត្តិការត្រួតពិនិត្យ ក្នុងនោះមាន មន្ត្រីពន្ធដារ និង មន្ត្រីមានសមត្ថកិច្ចដែលបានចូលរួម ។
- ២០% នៃប្រាក់រង្វាន់ សំរាប់បង្កើតមូលនិធិសោហ៊ុយចំណាយរបស់សាខាពន្ធដារខេត្ត-ក្រុង
- ១០% នៃប្រាក់រង្វាន់ សំរាប់បង្កើតមូលនិធិសោហ៊ុយចំណាយរបស់សាលាខេត្ត-ក្រុង ។
- ១០% នៃប្រាក់រង្វាន់ សំរាប់បង្កើតមូលនិធិសោហ៊ុយចំណាយរបស់សាលាខ័ណ្ឌ-ស្រុក ។

២-ប្រាក់ពិន័យដែលទទួលបានលើការត្រួតពិនិត្យក្នុងភូមិ ឃុំ-សង្កាត់ ដែលមានសហការរវាងមន្ត្រី ពន្ធដារ នគរបាលឃុំ-សង្កាត់ និង ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបានអនុញ្ញាតឱ្យដកចំនួន ៣៥% (សាមសិបប្រាំភាគរយ) លើប្រាក់ដែលពិន័យបាន សំរាប់ប្រើប្រាស់ជាប្រាក់រង្វាន់ ដោយត្រូវបែងចែក ដូចតទៅ :

-៦០% នៃប្រាក់រង្វាន់ សំរាប់ចែកជូនសមាជិកនៃក្រុមប្រតិបត្តិការត្រួតពិនិត្យ ក្នុងនោះមាន មន្ត្រីពន្ធដារ នគរបាលឃុំ-សង្កាត់ និង ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

-២០% នៃប្រាក់រង្វាន់ សំរាប់បង្កើតមូលនិធិសោហ៊ុយចំណាយ សំរាប់សាខាពន្ធដារខេត្ត-ក្រុង(១០%) សំរាប់នគរបាលឃុំ-សង្កាត់ (៥%) និងសំរាប់ក្រុមប្រឹក្សាឃុំ-សង្កាត់ (៥%)

-១០% នៃប្រាក់រង្វាន់ សំរាប់បង្កើតមូលនិធិសោហ៊ុយចំណាយរបស់សាលាខេត្ត-ក្រុង ។

-១០% នៃប្រាក់រង្វាន់ សំរាប់បង្កើតមូលនិធិសោហ៊ុយចំណាយរបស់សាលាខ័ណ្ឌ-ស្រុក ។

**ប្រការ ២ :** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០០៤

គាត ឈន់

**<u>កន្លែងទទួល:</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជារបាយការណ៍"
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង

  "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

  "ដើម្បីមុខការ"
- គ្រប់សាខាពន្ធដារខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៥ សហវ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០០៤

# សេចក្តីជូនដំណឹង

ដោយយោងតាមសេចក្តីជូនដំណឹងលេខ ០០១ សហវ.សជណ ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ២០០៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ម្ចាស់យានយន្តគ្រប់ប្រភេទមួយចំនួនដែលកន្លងមកខកខានពុំទាន់បានបំពេញកាតព្វកិច្ចពន្ធ និងអាករនាំចូលស្របតាមច្បាប់ជាធរមាននោះ បានចូលខ្លួនជាបន្តបន្ទាប់មកបំពេញបែបបទ និងបង់ពន្ធជូនរដ្ឋរួចហើយ ប្រកបដោយលទ្ធផលគួរឱ្យកត់សំគាល់ ។ ទន្ទឹមនឹងនេះ ក៏នៅមានម្ចាស់យានយន្តមួយចំនួនទៀតមិនទាន់បានចូលខ្លួនមកបំពេញកាតព្វកិច្ចពន្ធតាមការអញ្ជើញនៅឡើយ ។

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងដើម្បីសម្រួលដល់ម្ចាស់យានយន្តដែលខកខានមិនបានអនុវត្តតាមកាលកំណត់នៅឡើយនោះ មានលទ្ធភាពអាចបន្តចូលខ្លួនដោយស្ម័គ្រចិត្តមកបំពេញកាតព្វកិច្ចពន្ធបានផងនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំបន្ថែមដូចតទៅ ៖

១. ម្ចាស់យានយន្តទាំងឡាយណាដែលមានបំណងចូលខ្លួនមកបំពេញកាតព្វកិច្ចពន្ធ និងអាករនាំចូលលើយានយន្តរបស់ខ្លួន ត្រូវមកសុំការអនុញ្ញាតបង់ពន្ធរថយន្តរបស់ខ្លួនជាមុននៅនាយកដ្ឋានការិយាល័យ ឬសាខាគយ និងរដ្ឋាករកាត់ពន្ធ ។ ទទួលបានការអនុញ្ញាតពីមន្ត្រីគយនិងរដ្ឋាករដែលមានសមត្ថកិច្ចជាលាយលក្ខណ៍អក្សររួចហើយ ត្រូវប្រើប្រាស់យានយន្តនោះសំរាប់តែភ្ជាប់ជាមួយនាំមកបង្ហាញការិយាល័យ ឬសាខាគយ និងរដ្ឋាករកាត់ពន្ធដែលជិតបំផុត ដើម្បីធ្វើការត្រួតពិនិត្យបំពេញបែបបទពន្ធ និងបិតលេខាផ្ទុកស្លាក ។ ការបញ្ជាក់ពីការអនុញ្ញាតឱ្យចូលខ្លួនបង់ពន្ធនោះ ត្រូវមានសុពលភាពយ៉ាងយូរត្រឹម ០៧ ថ្ងៃប៉ុណ្ណោះ គិតពីកាលបរិច្ឆេទនៃការបញ្ជាក់នេះ ។

២. ចំពោះការគយនិងរដ្ឋាករ ត្រូវចាត់វិធានការនានាស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានកន្លងមក រួមទាំងការអនុវត្តនីតិវិធីនានាពាក់ព័ន្ធ ដើម្បីជំរុញឱ្យម្ចាស់យានយន្តដែលមិនទាន់បង់ពន្ធ អាករ និងប្រាក់ពិន័យនានាចូលថវិកាជាតិឱ្យមានប្រសិទ្ធភាពចាប់ពីពេលនេះតទៅ ។ ក្នុងករណីចាំបាច់ កិច្ចការនេះត្រូវធ្វើឡើងដោយមានកិច្ចសហការចូលរួមពីកំលាំងប្រដាប់អាវុធ និងអាជ្ញាធរមានសមត្ថកិច្ចជំនាញ ឬសមត្ថកិច្ចមូលដ្ឋានផងដែរ ស្របតាមខ្លឹមសារលិខិតបញ្ជាលេខ ០២ ប.ប ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការបង្កើនប្រសិទ្ធភាពនៃការទប់ស្កាត់ និងបង្ក្រាបអំពើរត់ពន្ធ ។

៣. កំលាំងអធិការកិច្ចការពារពន្ធដែលពាក់ព័ន្ធ ២ ខាងលើ និងត្រូវទទួលបានប្រាក់រង្វាន់លើកទឹកចិត្ត ស្របតាមខ្លឹមសារប្រកាសលេខ ២១១ សហវ.ប្រក.គ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្ឃឹមថា សេចក្តីណែនាំ និងវិធានការទាំងនេះនឹងទទួលបាននូវការឆ្លើយតបជាវិជ្ជមានពីភាគីពាក់ព័ន្ធ ដោយសូមចាត់ទុកថា ជាការចូលរួមដោយផ្ទាល់ក្នុងការកាត់បន្ថយនិងឈានទៅលុបបំបាត់អំពើល្មើសច្បាប់ ឬអំពើមិនប្រក្រតីនានាក្នុងសង្គមកម្ពុជា ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី ( ដើម្បីជូនជ្រាបជាពត៌មាន )
- ទីចាត់ការគយនិងរដ្ឋាករ ( ដើម្បីចាត់ចែង អនុវត្តតាមមុខការ )
- សភាពាណិជ្ជកម្មរាជធានីភ្នំពេញ
  ( ដើម្បីជ្រាបនិងផ្សព្វផ្សាយ )
- ឯកសារ-កាលប្បវត្តិ